សង្កាត់សាលារៀនអូកឡិនដ៍
សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ

ស្តីអំពីការពិនិត្យ និងការអនុម័តចុងក្រោយ នៃផែនការលៃទុកមូលនិធិ និងផែនការបំរើសេវាប្រចាំឆ្នាំ លើវិស័យរៀបចំគំរោងមូលដ្ឋានសំរាប់កម្មវិធីអប់រំពិសេស (SELPA) តាមការស្នើសុំ សំរាប់ឆ្នាំសិក្សា 2019-2020

ជូនចំពោះភាគីពាក់ពាន់ទាំងអស់៖

សូមធ្វើការកត់ចំណាំទុកថា នៅថ្ងៃទី 5 ខែមិថុនា ឆ្នាំ 2019 ក្រុមប្រឹក្សាគ្រប់គ្រងនៃសង្កាត់សាលារៀនអូកឡិនដ៍ នៅក្នុងកិច្ចប្រជុំធម្មតារបស់ខ្លួននេះ នឹងបើកសវនាការជាសាធារណៈមួយ ស្តីអំពីផែនការរៀបចំមូលនិធិ និងផែនការបំរើសេវាប្រចាំឆ្នាំ លើវិស័យរៀបចំគំរោងមូលដ្ឋានសំរាប់កម្មវិធីអប់រំពិសេស តាមសំណើសុំរបស់ខ្លួន សំរាប់ឆ្នាំសិក្សា 2019-2020 ហើយនៅចុងបញ្ចប់នៃសវនាការ នឹងត្រូវបានដាក់ស្នើសុំការអនុម័ត / សច្ចានុមតិដ៏ចក្លា ពីសំណាក់ក្រុមប្រឹក្សាគ្រប់គ្រង។

សវនាការសាធារណៈ នឹងត្រូវបានធ្វើនៅថ្ងៃទី 5 ខែមិថុនា ឆ្នាំ 2019 នៅម៉ោង 6:00 ល្ងាច ឬបន្ទាប់ពីម៉ោងហ្នឹងភ្លាមៗតែម្តង នៅក្នុងបន្ទប់ Great Room នៃមជ្ឈមណ្ឌល LaEscuelita Education Center នៅ 1050 2nd Avenue, Oakland, CA 94606-2212។

គោលបំណងនៃសវនាការសាធារណៈនេះ គឺដើម្បីប្រមូលមតិយោបល់ពីសាធារណជន អំពីផែនការរៀបចំមូលនិធិ និងការបំរើសេវាប្រចាំឆ្នាំ និងដើម្បីធ្វើការកែសម្រួលដល់ផ្នែកហ្នឹងដែរ បើសិនជាមានការអនុញ្ញាត។

ផែនការនានាមួយច្បាប់ នឹងមានដាក់ចែកជូនសំរាប់ធ្វើការពិនិត្យមើល នៅកន្លែងដាក់កំព្យូទ័រឱ្យប្រើប្រាស់ នៅមុនមានការបើកសវនាការជាសាធារណៈមួយ នៅក្នុងការិយាល័យនៃសង្កាត់សាលារៀនអូកឡិនដ៍ មានដូចតទៅនេះ៖ ការិយាល័យនៃក្រុមប្រឹក្សាគ្រប់គ្រង និងការិយាល័យនៃអគ្គនាយកនៃសង្កាត់សាលារៀន នៅ 1000 Broadway, Suite 680, Oakland, CA 94607-4099 និងនៅការិយាល័យនៃនាយកដ្ឋាននៃកម្មវិធីកុមារពិសេស នៅសាលា Cole Elementary School Site, 1011 Union Street, Oakland, CA 94607-2236 ហើយនៅថ្ងៃទី 17 ខែឧសភា ឆ្នាំ 2019 នឹងមានដាក់ជូនលើគេហទំព័រ http://www.ousd.org/domain/69 ។

s/ Kyla Johnson-Trammell
លេខាធិការ, ក្រុមប្រឹក្សាគ្រប់គ្រង
សង្កាត់សាលារៀនអូកឡិនដ៍